**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងយុត្តិធម៌

លេខ ១០៥៩.រប.៦១០៦-៩៤

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**សូមជម្រាបមក**

**លោក ប្រធានតុលាការ ខេត្ត ក្រុង**

**លោកព្រះរាជអជ្ញាអមតុលាការ ខេត្ត ក្រុង**

**សូមជ្រាប។**

**កម្មវត្ថុ:** ភារកិច្ចរបស់អយ្យការក្នុងករណីផ្ទេរទណ្ឌិត ពីពន្ធនាគារមួយទៅពន្ធនាគារមួយទៀត ។

ខ្ញុំសូមជម្រាបមកលោកប្រធានតុលាការគ្រប់ខេត្ត ក្រុងថា តុលាការស្ថាប័នមួយមានភារកិច្ចជំនុំជម្រះរឿងក្តីគ្រប់ប្រភេទ ក្នុងក្របខ័ណ្ឌអំណាចតុលាការដែលមានចែងក្នុងមាត្រា ១០៩ នៃរដ្ឋធម្មនុញ្ញ ។ផ្នែកខាងរឿងអាជ្ញាកិច្ចការជំនុំជម្រះនៃតុលាការត្រូវប្រព្រឹត្តទៅក្រោយពីមានបណ្តឹងពីស្ថាប័នអយ្យការអមតុលាការ ឬក៏ថាពីអយ្យការធ្វើការក្បែរតុលាការដើម្បីប្តឹងចោទលើជនប្រព្រឹត្តបទល្មើស ចង្អុលភស្តុតាងផ្សេងៗដើម្បីបញ្ជាក់អំពីពិរុទ្ធភាពហើយសុំឲ្យតុលាការយកបញ្ញត្តិច្បាប់មកអនុវត្តធ្វើទោសដល់មនុស្សត្រូវចោទនោះ ។

ខ្ញុំសូមបញ្ជាក់ថា កិច្ចការស្វែងរកមនុស្សប្រព្រឹត្តបទល្មើសមាន មន្ត្រីភ្នាក់ងារនគរបាលយុត្តិធម៌ជាអ្នកបំពេញភារកិច្ចក្រោមការណែនាំរបស់ព្រះរាជអាជ្ញា ។

ចាប់តាំងពីមនុស្សត្រូវចោទជាប់ឃុំឃាំងជាបណ្តោះអាសន្នដល់ជននេះត្រូវទទួការកាត់ទោស ហើយក្លាយទៅជាទណ្ឌិតទទួលទោសនៅក្នុងពន្ធនាគារនោះព្រះរាជអាជ្ញាមានភារកិច្ចតាមឃ្លាំមើលការអនុវត្ត នៃនាយផ្នែកពន្ធនាគារជារៀងរហូត ។

ដូច្នេះក្នុងករណីផ្ទេរទណ្ឌិតពីពន្ធនាគារមួយទៅពន្ធនាគារផ្សេងមួយទៀតជាភារកិច្ចត្រួតពិនិត្យ និងឃ្លាំមើលរបស់អយ្យការ ដែលអ្នកសរសេររាយការណ៍ទៅក្រសួងយុត្តិធម៌និងទៅមហាអយ្យការអមសាលាឧទ្ធរណ៍ដែលជាស្ថាប័នថ្នាក់លើនៃឋានានុក្រម ពុំមែនជាភារកិច្ចរបស់ប្រធានតុលាការទេ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៩៤

**រដ្ឋមន្ត្រី**

**ចែម ស្គួន**